# បច្ចេកទេសបណ្តុះផ្សិតអំបោះ ផ្សិតខ្យង និងផ្សិតចំបើង



នាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំ

ឧបត្ថម្ភ ៖ **គម្រោងជំរុញផលិតកម្មស្បៀង**
**នៃអគ្គនាយកដ្ឋានកសិកម្ម**
**ឆ្នាំ ២០១៦**

# មាតិកាអត្ថបទ


***បច្ចេកទេសបណ្តុះផ្សិតអំបោះ និងផ្សិតខ្យង............1***

១. សេចក្តីផ្តើម............1

២. ការជ្រើសរើសទីកន្លែងសង់រោង............1

៣. ការសាងសង់រោងបណ្តុះផ្សិត............2

៤. ការជ្រើសរើសវត្ថុធាតុដើម............2

៥. សម្ភារៈប្រើប្រាស់............3

៦. រូបមន្តល្បាយផ្សំ............3

៦.១. ការផលិតអំពីអាចម៍រណា............3

៦.២. វិធីលាយវត្ថុធាតុផ្សំដោយមិនចាំបាច់ផ្អាប់............3

៦.៣. វិធីផ្អាប់វត្ថុធាតុផ្សំ............4

៦.៤. វិធីច្រកល្បាយផ្សំបញ្ចូលក្នុងថង់............4

៧. វិធីចំហុយល្បាយផ្សំ............5

៨. ការបញ្ចូលមេផ្សិត............6

៨.១. សម្ភារៈសម្រាប់បញ្ចូលមេផ្សិត............6

៨.២. វិធីបញ្ចូលមេផ្សិត............6

៩. ការបង្កុំក្នុងរោង............6

១០. ការតម្រៀបព្យួរដុំល្បាយផ្សំ............7

១០.១. សម្ភារៈប្រើប្រាស់ក្នុងរោងបណ្តុះ............7

១០.២. របៀបព្យួរដុំល្បាយផ្សំ............7

១១. វិធីថែទាំដុំផ្សិតក្រោយការប្រមូលផល............8

១២. កត្តាចង្រៃ ជម្ងឺ និងការការពារ............8

១២.១. សត្វល្អិត............8

១២.២. ពីងពាង............9

១២.៣. ជន្លូង............9

១២.៤. ខ្យង............9

១២.៥. កណ្តៀរ............9

១២.៦. ពពួកផ្សិតទ្រីកូឌែម៉ា............10

១២.៩. ផ្សិត Penicillium spp ( ផ្សិតប៉េនីស៊ីល្យូម )............10

១៣. ការកែច្នៃផ្សិតសម្រាប់រក្សាទុកបានយូរ............10

១៣.១.ការសម្ងួត............10

១៣.២. ជ្រក់ផ្សិត............11

## បច្ចេកទេសបណ្តុះផ្សិតចំបើង ....................................................... 12


១. សេចក្តីផ្តើម ........................................................ 12

១.១. លក្ខណៈទូទៅ ........................................................ 12

១.២. សារធាតុចិញ្ចឹម ........................................................ 12

១.៣. លក្ខណៈជីវសាស្ត្រ ........................................................ 13

២. របៀបបណ្តុះបែបសាមញ្ញ(មិនចំហុយ) ........................................................ 14

២.១. ការជ្រើសរើសទីកន្លែង ........................................................ 14

២.២. ការត្រៀមសម្ភារៈ និងវត្ថុធាតុដើម ........................................................ 14

២.៣. ការរៀបចំដីធ្វើរង ........................................................ 15

២.៤. ការរៀបចំបណ្តុះផ្សិត ........................................................ 16

២.៥. ការថែទាំ ........................................................ 17

៣. របៀបបណ្តុះដោយចំហុយចំណីផ្សិត ........................................................ 18

៣.១. វត្ថុធាតុផ្សំ ........................................................ 18

៣.២. សម្ភារៈ ........................................................ 18

៣.៣. ការលាយវត្ថុធាតុផ្សំដុំល្បាយ ........................................................ 19

៣.៤. ការរៀបចំដុំល្បាយបណ្តុះផ្សិត ........................................................ 20

៣.៥. ការចំហុយដុំល្បាយបណ្តុះផ្សិត ........................................................ 21

៣.៦. ការបញ្ចូលមេផ្សិត ទៅក្នុងដុំល្បាយបណ្តុះ ........................................................ 22

៣.៧. ការរៀបចំដុំល្បាយបណ្តុះក្នុងរោង ........................................................ 22

៤. កត្តាចង្រៃ សត្វល្អិត ជម្ងឺ និងការគ្រប់គ្រង ........................................................ 23

៤.១. ការកំចាត់សត្វល្អិតនៅក្នុងដី ........................................................ 23

៤.២. ជម្ងឺ ........................................................ 25

៥. ការប្រមូលផល ........................................................ 28

៦. ការកែច្នៃផ្សិត ........................................................ 29

ឯកសារយោង ........................................................ 30

# អារម្ភកថា

សៀវភៅឈ្មោះជាភាសាខ្មែរនិងភាសាអង់គ្លេសអមដោយរូបភាពរបស់ដំណាំបន្លែ នៃគ្រួសារនីមួយៗក្នុងប្រទេសកម្ពុជានេះត្រូវបានប្រមូលផ្តុំ និងរៀបរៀងឡើងដោយនាយកដ្ឋានសាកវប្បកម្មនិងដំណាំរួមផ្សំនៃអគ្គនាយកដ្ឋានកសិកម្ម។

សៀវភៅនេះមានបំណងផ្តល់ជូនអ្នកអាននូវ គំនិតខ្លះៗដែលយើងខ្ញុំបានចងក្រងឡើងវិញនូវឈ្មោះដែល អមដោយរូបភាពដើម្បីមិត្តអ្នកអានងាយយល់។ ដោយយោងទៅលើការខ្វះខាតឯកសារជាភាសាខ្មែរនិងដោយឯកសារដែលមាននាពេលបច្ចុប្បន្ននេះច្រើនជាភាសាបរទេសដែលធ្វើឱ្យសិស្សនិស្សិត និងអ្នកមើលមានការលំបាកយល់ ឬមិនអាចយល់បានតែម្តងដូចនេះ ទើបនាយកដ្ឋានសាកវប្បកម្មនិងដំណាំរួមផ្សំ នៃអគ្គនាយកដ្ឋានកសិកម្មបានផ្តួចផ្តើមទាំងគំនិតនិងផ្តល់ទាំងថវិកាដើម្បីរៀបចំសៀវភៅនេះឡើង។

សៀវភៅនេះមិនបានធ្វើអត្ថាធិប្បាយឱ្យបានពិស្តារច្រើនពីប្រភេទដំណាំនីមួយៗ នោះទេប៉ុន្តែវាបានរៀបរាប់នូវឈ្មោះនិងរូបភាពគោលសំខាន់ៗលើដំណាំបន្លែក្នុងប្រទេសកម្ពុជាដែលប្រជាកសិករធ្វើការដាំដុះនាពេលបច្ចុប្បន្ន។ សៀវភៅនេះនៅមានការខ្វះចន្លោះមួយចំនួនដែលនាយកដ្ឋានសាកវប្បកម្មនិងដំណាំរួមផ្សំនឹងបំពេញបន្ថែមឬក៏កែលម្អនៅពេលអនាគតស្របតាមបរិបទបច្ចេកវិទ្យាជឿនលឿនព្រមទាំងទទួលបាននូវព័ត៌មាន ឬ ទិន្នន័យផ្សេងៗពីការសិក្សាស្រាវជ្រាវបន្ថែមទៀត។

នាយកដ្ឋានសាកវប្បកម្មនិងដំណាំរួមផ្សំសង្ឃឹមថាសៀវភៅនេះនឹងបានចូលរួមជាជំនួយខ្លះៗចំពោះអ្នកអានសម្រាប់ជាប្រទីបឬជាពុទ្ធិផ្ទាល់ខ្លួនឬសម្រាប់អប់រំផ្សព្វផ្សាយបន្ត។

ជាមួយគ្នានេះក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានកសិកម្មដែលបានជំរុញអោយមានការបោះពុម្ពនេះឡើង។

សូមថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំ និងមន្ត្រីរបស់នាយកដ្ឋានសាកវប្បកម្មនិងដំណាំរួមផ្សំដែលបានជួយជ្រុំជ្រែងផ្តល់ជាគំនិតយោបល់ដើម្បីកើតចេញជាសៀវភៅនេះឡើង។

រាជធានីភ្នំពេញ, ខែកុម្ភៈ ឆ្នាំ២០១៦

អគ្គនាយកដ្ឋានកសិកម្ម

ម.ព.ឯ.ក AIDOC
Code: 244-020
Date:
Donated by:

# បច្ចេកទេសបណ្ដុះផ្សិតអំបោះ និងផ្សិតខ្យង

## ១. សេចក្ដីផ្ដើម

ផ្សិតជាប្រភេទរុក្ខជាតិម្យ៉ាងដែលមានអាហាររូបត្ថម្ភខ្ពស់សម្រាប់ទ្រទ្រង់សុខមាលភាពមនុស្ស និងជាពិសេសវាជាប្រភេទដំណាំដែលឆាប់បានផល។ ហើយផលិតផលទាំងនោះនឹងជួយបង្កើនប្រាក់ចំណូលក្នុងគ្រួសារកសិករ។ ផ្កាផ្សិតមានរសជាតិស្រាល ឆ្ងាញ់ ហើយសំបូរដោយសារធាតុចិញ្ចឹម។ ផ្កាផ្សិតស្រស់មានប្រូតេអ៊ីន ៣ ទៅ ៤% ហើយមានអាមីណូអាស៊ីត ១៨ប្រភេទ។ លើសពីនេះទៅទៀត វាមានផ្ទុកនូវវីតាមីនបេ វីតាមីនសេ នីកូទីណេត និងសារធាតុរ៉ែដូចជា ដែក ម៉ង់កាណែស ស័ង្កសី និងម៉ាញ៉េស្យូម។ ការស្រាវជ្រាវបានបង្ហាញថាវាអាចកាត់បន្ថយជាតិខ្លាញ់ និងបញ្ចៀសជម្ងឺសំពាធឈាមឡើងខ្ពស់ ជម្ងឺបេះដូង និងសសៃឈាម។ សារធាតុប៉ូលីសាការីតក្នុងផ្សិតអាចជួយបង្កើនសមត្ថភាពប្រព័ន្ធភាពស៊ាំរាងកាយ។



ផ្សិតអំបោះ



ផ្សិតខ្យង

## ២. ការជ្រើសរើសទីកន្លែងសង់រោង

ជាទូទៅផ្សិតច្រើនដុះនៅលើកំទេចឈើដែលពុករលួយនៅក្នុងលក្ខ័ណ្ឌអាកាសធាតុ ( សំណើម និងកំដៅ ) សមស្របទៅតាមប្រភេទផ្សិតនីមួយៗ។ ផ្សិតអំបោះ និងផ្សិតខ្យងអាចធ្វើការបណ្ដុះបាននៅលើល្បាយផ្សំពីកំទេចឈើលាយជាមួយសារធាតុរ៉ែមួយចំនួនទៅតាមរូបមន្ត ដែលបានសិក្សាស្រាវជ្រាវអំពីដំណើរការលូតលាស់របស់ផ្សិតជា លក្ខណៈធម្មជាតិ។

ទីកន្លែងសម្រាប់សង់រោងបណ្ដុះផ្សិតអំបោះត្រូវមានលក្ខណៈដូចជា៖

- ដីទួលមិនលិចទឹក ហើយនៅក្បែរលំនៅដ្ឋាន
- មានប្រភពទឹកស្អាតសម្រាប់ប្រើប្រាស់
- បរិយាកាសជុំវិញល្អប្រសើរ
- ផ្ទៃដីជុំវិញវាលទូលាយ និងមានចង្អូរសម្រាប់បង្ហូរទឹក

- ផ្ទៃបាតរោងត្រូវចាក់ខ្សាច់កំរាស់ ១០សង្ទីម៉ែត្រ ( ១តឹក ) ដើម្បីទឹកជ្រាបលឿន និងរក្សាសំណើមក្នុងរោង អោយមានភាពត្រជាក់ល្អ។

## ៣. ការសាងសង់រោងបណ្តុះផ្សិត

- រោងផ្សិតអំបោះមានទំហំប្រែប្រួលទៅតាមតម្រូវការនៃចំនួនថង់ដុំល្បាយដែលត្រូវរៀបចំបណ្តុះ។
- ទំហំរោងផ្សិតសម្រាប់រៀបចំបណ្តុះចំនួន ៥០០០ថង់ ដុំល្បាយត្រូវមានទំហំ ៥ម៉ែត្របួនជ្រុង និងកំពស់ ជញ្ជាំង ប្រវែង ២ម៉ែត្រកន្លះទៅ ៣ម៉ែត្រ (៥ម X ៥ម X ២,៥ម - ៣ម )។
- ដំបូលរោងស្លឹកត្រូវប្រក់ស្លឹកត្នោត ឬ ស្បូវ និងជញ្ជាំងបាំងស្លឹកស្បូវ ឬ បាំងក្រណាត់។

## ៤. ការជ្រើសរើសវត្ថុធាតុដើម

**វត្ថុធាតុដើមសម្រាប់ដាំផ្សិតអំបោះមាន :** អាចម៍រណាដើមកៅស៊ូ ឬ ប្រភេទឈើដែលមានសាច់ទន់ដូចជា អាចម៍រណាដើមស្វាយដើមដំឡូងឈើ ចំបើង ស្នូលពោត អង្កាមគ្រាប់កប្បាសជាដើម។



អាចម៍រណា



ចំបើង



អង្កាមគ្រាប់កប្បាស



ស្នូលពោត